**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.........✓...........ន. គ. ស .......

ថ្ងៃសុក្រ ១១កើតខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យាពេលក្នុងការរៀបចំវគ្គបណ្តុះបណ្តាល
## មូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យ

**និយ័តករគណនេយ្យនិងសវនកម្ម** នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជន និងសិក្ខាកាមទាំងអស់ដែលបានចុះឈ្មោះចូលរួមសិក្សា វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យ មេត្តាជ្រាបថា ÷ វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យ ដែលនឹងត្រូវរៀបចំនៅ ថ្ងៃទី២៣-២៥ ខែមេសា ឆ្នាំ២០២៤ ត្រូវបានពន្យារពេល ដោយហេតុថា **និយ័តករគណនេយ្យនិងសវនកម្ម** ចង់ផ្តល់ព័ត៌មាននិងពេលវេលាបន្ថែមជូនដល់សាធារណៈជន ដែលមានបំណងចូលរួមសិក្សាស្វែងយល់អំពី មូលដ្ឋានគ្រឹះគណនេយ្យ តែមិនទាន់បានចុះឈ្មោះនៅឡើយអាចធ្វើការចុះឈ្មោះបាន។

ក្នុងន័យនេះ **និយ័តករគណនេយ្យនិងសវនកម្ម** សូមលើកពេលវេលានៃវគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យទៅ **ថ្ងៃទី២៧-២៩ ខែឧសភា ឆ្នាំ២០២៤** វិញ។

អាស្រ័យហេតុនេះ សូមសាធារណៈជន និងសិក្ខាកាមទាំងអស់មេត្តាជ្រាបជាព័ត៌មាននិងសូមចូលរួមវគ្គបណ្តុះបណ្តាលខាងលើតាមពេលកំណត់ដូចមានខ្លឹមសារក្នុងសេចក្តីជូនដំណឹងនេះ។

**និយ័តករគណនេយ្យនិងសវនកម្ម**

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង÷**

កញ្ញា សុខ ណារី ÷០៦៩ ៥៥១ ៥០៧

លោក ឡាយ វិចិត្រ ÷០៩៥ ៧០១ ៩៧០

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111